# ព្រះរាជាណាចក្រកម្ពុជា
## ជាតិ សាសនា ព្រះមហាក្សត្រ

**អគ្គនាយកដ្ឋានគយនិងរដ្ឋាករកម្ពុជា**

**លេខ : ២៩៩៦/២១ អ គ រ**

ថ្ងៃ សុក្រ ១២រោច ខែមិគសិរ ឆ្នាំឆ្លូវ ត្រីស័ក ព.ស.២៥៦៥

រាជធានីភ្នំពេញ ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២១

**ជម្រាបមក**

**លោក លោកស្រី ប្រធាននាយកដ្ឋាន សាខា និងការិយាល័យគយនិងរដ្ឋាករ**

**កម្មវត្ថុ:** ការបន្ថែមឯកតារង (Supplementary Unit) លើមុខទំនិញផលិតផលតេលសិលាមួយចំនួន នៃតារាងពន្ធគយកម្ពុជាឆ្នាំ២០២២ ក្នុងប្រព័ន្ធអាស៊ីគូដា។

**យោង:**
- ប្រកាសលេខ ១៤៤៧ សហវ.ប្រក ចុះថ្ងៃទី២៦ ខែធ្នូ ឆ្នាំ២០០៧ ស្ដីពីបញ្ញត្តិនិងនីតិវិធីប្រតិវេទន៍គយ
- ប្រកាសលេខ ៧៨២ សហវ.ប្រក ចុះថ្ងៃទី២២ ខែវិច្ឆិកា ឆ្នាំ២០២១ ស្ដីពីការដាក់ឱ្យប្រើប្រាស់តារាងពន្ធគយកម្ពុជាឆ្នាំ២០២២។

សេចក្ដីដូចមានចែងក្នុងកម្មវត្ថុនិងយោងខាងលើ ខ្ញុំសូមជម្រាបលោក លោកស្រីជ្រាបថា ដើម្បីធានាសង្គតិភាពនៃការគណនាប្រាក់ពន្ធនិងអាករលើមុខទំនិញផលិតផលតេលសិលាមួយចំនួន អគ្គនាយកដ្ឋានគយនិងរដ្ឋាករកម្ពុជា សម្រេចបន្ថែមនូវឯកតារង (Supplementary Unit) គិតជាលីត្រ (LTR) លើមុខទំនិញផលិតផលតេលសិលាចំនួន១៧បន្ទាត់ពន្ធនៃតារាងពន្ធគយកម្ពុជាឆ្នាំ២០២២ ជាធរមាន នៅក្នុងប្រព័ន្ធអាស៊ីគូដា ដែលមានទីតាំងរងលេខ÷ ២៧១០.១២.១១ ២៧១០.១២.១២ ២៧១០.១២.១៣ ២៧១០.១២.២១ ២៧១០.១២.២២ ២៧១០.១២.២៣ ២៧១០.១២.២៤ ២៧១០.១២.២៥ ២៧១០.១២.២៦ ២៧១០.១២.២៧ ២៧១០.១២.២៨ ២៧១០.១២.២៩ ២៧១០.១២.៣១ ២៧១០.១២.៣៩ ២៧១០.១៩.៧១ ២៧១០.១៩.៧២ និង ២៧១០.១៩.៧៩ ។

អាស្រ័យហេតុនេះ សូមលោក លោកស្រីចាត់ចែងអនុវត្តឱ្យមានប្រសិទ្ធភាពចាប់ពីថ្ងៃទី០១ ខែមករា ឆ្នាំ២០២២ នេះតទៅ។

សូមលោក លោកស្រីទទួលនូវការស្រឡាញ់រាប់អានពីខ្ញុំ

**រដ្ឋមន្ត្រីប្រតិភូអមនាយករដ្ឋមន្ត្រី**
**អគ្គនាយកគយនិងរដ្ឋាករកម្ពុជា**

បណ្ឌិត គុណ ញឹម

**ចម្លងជូន÷**
- ខុទ្ទកាល័យឯកឧត្តមអគ្គបណ្ឌិតសភាចារ្យ ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ "ដើម្បីជូនជ្រាប"
- សភាពាណិជ្ជកម្មកម្ពុជា "ដើម្បីសហការផ្សព្វផ្សាយ"
- ឯកសារ- កាលប្បវត្តិ

| | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|
| | 2710.12.11 | - - - - ដែលមានកម្រិតអុកតាន ៩៧ និងលើស | - - - - Of RON 97 and above | kg | 15<br>0.02$/l | 20 | 10 | 0 | |
| | 2710.12.12 | - - - - ដែលមានកម្រិតអុកតាន ៩០ និងលើស តែតិចជាងអុកតាន ៩៧ | - - - - Of RON 90 and above but below RON 97 | kg | 15<br>0.02$/l | 20 | 10 | 0 | |
| | 2710.12.13 | - - - - ដែលមានកម្រិតអុកតានផ្សេងទៀត | - - - - Of other RON | kg | 15<br>0.02$/l | 20 | 10 | 0 | |
| | | - - - ប្រេងសាំង គ្មានជាតិសំណ ៖ | - - - Motor spirit, unleaded : | | | | | | |
| | | - - - - ដែលមានកម្រិតអុកតាន ៩៧ និងលើស ៖ | - - - - Of RON 97 and above : | | | | | | |
| | 2710.12.21 | - - - - - គ្មានលាយសមាសធាតុជំនួយ | - - - - - Unblended | kg | 15<br>0.02$/l | 20 | 10 | 0 | |
| | 2710.12.22 | - - - - - លាយអេតាណុល | - - - - - Blended with ethanol | kg | 15<br>0.02$/l | 20 | 10 | 0 | |
| | 2710.12.23 | - - - - - ផ្សេងទៀត | - - - - - Other | kg | 15<br>0.02$/l | 20 | 10 | 0 | |
| | | - - - - ដែលមានកម្រិតអុកតាន ៩០ និងលើសពីនេះ តែតិចជាង ៩៧ ៖ | - - - - Of RON 90 and above but below RON 97 : | | | | | | |
| | 2710.12.24 | - - - - - គ្មានលាយសមាសធាតុជំនួយ | - - - - - Unblended | kg | 15<br>0.02$/l | 20 | 10 | 0 | |
| | 2710.12.25 | - - - - - លាយអេតាណុល | - - - - - Blended with ethanol | kg | 15<br>0.02$/l | 20 | 10 | 0 | |
| | 2710.12.26 | - - - - - ផ្សេងទៀត | - - - - - Other | kg | 15<br>0.02$/l | 20 | 10 | 0 | |
| | | - - - - ដែលមានកម្រិតអុកតានផ្សេងទៀត ៖ | - - - - Of other RON : | | | | | | |
| | 2710.12.27 | - - - - - គ្មានលាយសមាសធាតុជំនួយ | - - - - - Unblended | kg | 15<br>0.02$/l | 20 | 10 | 0 | |
| | 2710.12.28 | - - - - - លាយអេតាណុល | - - - - - Blended with ethanol | kg | 15<br>0.02$/l | 20 | 10 | 0 | |
| | 2710.12.29 | - - - - - ផ្សេងទៀត | - - - - - Other | kg | 15<br>0.02$/l | 20 | 10 | 0 | |
| | | - - - ប្រេងយន្តហោះនៃប្រភេទប្រើសម្រាប់ចាក់ម៉ាស៊ីនយន្តហោះប្រើពីស្តុង ៖ | - - - Aviation spirit, of a kind used in aviation piston-engines : | | | | | | |
| | 2710.12.31 | - - - - ១០០ អុកតាន និងលើស | - - - - 100 octane and above | kg | 0 | 15 | 10 | 0 | |
| | 2710.12.39 | - - - - ផ្សេងទៀត | - - - - Other | kg | 0 | 15 | 10 | 0 | |
| | 2710.19.71 | - - - - ប្រេងម៉ាស៊ូតសម្រាប់យានយន្ត | - - - - Automotive diesel fuel | kg | 0<br>0.04$/l | 7 | 10 | 0 | |
| | 2710.19.72 | - - - - ប្រេងម៉ាស៊ូតផ្សេងទៀត | - - - - Other diesel fuels | kg | 00.04$/l | 7 | 10 | 0 | |
| | 2710.19.79 | - - - - ប្រេងខ្មៅ | - - - - Fuel oils | kg | 0 | 0 | 10 | 0 | |

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

លេខ: ៩២២៨...សហវ.ប្រក.

រាជធានីភ្នំពេញ ថ្ងៃទី ២៦ ខែ ធ្នូ ឆ្នាំ ២០០៧

# ប្រកាស
## ស្តីពី
## បញ្ញត្តិ និងនីតិវិធីប្រតិវេទន៍គយ

### ទេសរដ្ឋមន្ត្រី
### រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស / រកត / ០៧០៤ / ១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពី ការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រ កម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២ / នស / ៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែល ប្រកាសឲ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស / រកម / ០១៩៦ / ១៨ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៧០៧/០១៧ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ២០០៧ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីគយ
- បានឃើញអនុក្រឹត្យលេខ ០៤ អនក្រ.បក ចុះថ្ងៃទី ២០ ខែ មករា ឆ្នាំ ២០០០ ស្តីពី ការរៀបចំ និងការប្រព្រឹត្តទៅនៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- យោងតាមសំណូមពរការងារចាំបាច់របស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

## <u>សម្រេច</u>

**ប្រការ ១.-**

រាល់ទំនិញនាំចេញ ឬនាំចូលទោះជាជាប់ពន្ធ និងអាករក្តី ឬត្រូវបានលើក លែងពន្ធ និងអាករ ទំនិញទាំងនោះត្រូវតែជាកម្មវត្ថុនៃការធ្វើប្រតិវេទន៍គយ។



ផ្លូវលេខ ៩២ សង្កាត់វត្តភ្នំ ខណ្ឌដូនពេញ រាជធានីភ្នំពេញ កម្ពុជា
St.92, Sangkat Wat Phnom, Khan Daun Penh, Phnom Penh, CAMBODIA.
ទូរស័ព្ទ : ៨៥៥-២៣-៧២៤ ៦៦៤ ទូរសារ : ៨៥៥-២៣-៤២៧ ៧៩៨
Phone: 855-23-724 664 Fax: 855-23-427 798

ប្រតិវេទន៍គយគឺជាឯកសាររដ្ឋបាលតែមួយ (Single Administrative Document –SAD) ដែលមានកំណត់ពន្យល់ដូចមានចែងក្នុងឧបសម្ព័ន្ធ ក នៃប្រកាសនេះ ។

នាយកទីចាត់ការគយ និងរដ្ឋាករ អាចកំណត់ទម្រង់ប្រតិវេទន៍គយផ្សេងទៀតសម្រាប់តម្រូវការនៃការនាំចេញ នាំចូលរបស់អ្នកដំណើរ កញ្ចប់ប្រៃសណីយ៍ និងគោលបំណងផ្សេងទៀតតាមការចាំបាច់ ។

ប្រតិវេទន៍គយ ដែលត្រូវបានចុះបញ្ជិការដោយគយ គឺជាឯកសារត្រឹមត្រូវតាមច្បាប់តែមួយគត់ ដែលអាចត្រូវបានយកទៅប្រើប្រាស់ ដើម្បីជូនជាសំអាងថាទំនិញនោះត្រូវបាននាំចូលមកក្នុង ឬត្រូវបាននាំចេញពីកម្ពុជា ។

**ប្រការ ២.-**

ប្រតិវេទន៍គយ ត្រូវដាក់នៅការិយាល័យគយមានការអនុញ្ញាត ដែលកំណត់ដោយនាយកទីចាត់ការគយនិងរដ្ឋាករ ។

ប្រតិវេទន៍គយ អាចត្រូវបានដាក់នៅការិយាល័យគយ មុនពេលការមកដល់នៃទំនិញប្រសិនបើមានការអនុញ្ញាតជាមុនពីទីចាត់ការគយ និងរដ្ឋាករ ។

ចំពោះការនាំចូល:

ក. នៅពេលដែលទំនិញមិនត្រូវបានរាយការណ៍ដល់គយនៅលើប្រតិវេទន៍បំព្រួញ ប្រតិវេទន៍គយត្រូវដាក់នៅការិយាល័យគយនាពេលដែលទំនិញមកដល់ វៀរលែងតែមានការអនុញ្ញាតឲ្យដាក់ប្រតិវេទន៍មុនពេលទំនិញមកដល់ ស្របតាមកថាខ័ណ្ឌ ២ នៃប្រការនេះ ។ ប្រសិនបើទំនិញមកដល់មុនពេលចាប់ផ្តើមប្រតិបត្តិការរបស់ការិយាល័យគយ ប្រតិវេទន៍គយត្រូវតែដាក់ភ្លាមនៅពេលចូលធ្វើការ ។

ខ. ក្នុងករណីដែលទំនិញត្រូវបានរាយការណ៍ដល់គយនៅលើប្រតិវេទន៍បំព្រួញ ប្រតិវេទន៍គយត្រូវតែដាក់នៅការិយាល័យគយក្នុងរយៈពេលបី (៣) ថ្ងៃគត់ បន្ទាប់ពីទំនិញមកដល់ វៀរលែងតែទំនិញនោះត្រូវបានដាក់បញ្ចូលក្នុងសន្និធិគយបណ្តោះអាសន្ន ឬត្រូវបានដាក់ក្រោមនីតិវិធីធ្វើកាត់ ។

ចំពោះការនាំចេញ ប្រតិវេទន៍គយត្រូវដាក់ស្របតាមលក្ខខណ្ឌដូចមានចែងក្នុងវាក្យខ័ណ្ឌ ក កថាខ័ណ្ឌ ៣ នៃប្រការនេះ ដោយរាប់បញ្ចូលទាំងការដាក់ប្រតិវេទន៍គយមុនពេលទំនិញមកដល់ ។

**ប្រការ ៣.-**

ទំនិញនាំចេញ ឬនាំចូល ត្រូវប្រកាសដោយម្ចាស់ទំនិញ ឬដោយបុគ្គលដែលបានទទួលការអនុញ្ញាតឲ្យបំពេញបែបបទគយក្នុងនាមម្ចាស់ទំនិញ ។

បុគ្គលដែលបានទទួលការអនុញ្ញាតឲ្យបំពេញបែបបទគយ រួមមាន ៖

- បុគ្គលដែលបានទទួលកាអនុញ្ញាតជាជើងសារគយ ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ។

- បុគ្គលណាដែលគ្មានវិជ្ជាជីវៈជាជើងសារគយ អាចបំពេញប្រតិវេទន៍គយបានសម្រាប់អាជីវកម្មរបស់ខ្លួន ។ បុគ្គលនេះ អាចទទួលបានការអនុញ្ញាតឲ្យបញ្ចេញទំនិញពីគយសម្រាប់អ្នកដទៃបាន សម្រាប់ប្រតិបត្តិការពាក់ព័ន្ធនឹងទំនិញដោយឡែកមួយចំនួនជាបណ្ដោះអាសន្ន ប្រសិនបើមានការអនុញ្ញាតពីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ។

**ប្រការ ៤.-**

ប្រតិវេទន៍គយ ត្រូវធ្វើឡើងជាលាយល័ក្ខអក្សរ ឬ តាមមធ្យោបាយអេឡិកត្រូនិក។ បញ្ញត្តិ និងលក្ខខណ្ឌ សម្រាប់ការដាក់ប្រតិវេទន៍គយ និងឯកសារពាក់ព័ន្ធតាមមធ្យោបាយអេឡិកត្រូនិកមានចែងក្នុងឧបសម្ព័ន្ធ ខ នៃប្រកាសនេះ ។

សម្រាប់គោលបំណងនៃការអនុវត្តច្បាប់ និងបទបញ្ញត្តិគយជាធរមាន និងសម្រាប់គោលបំណងស្ថិតិ ប្រតិវេទន៍គយ ត្រូវមានចុះរាល់សូចនាចាំបាច់ស្របតាមការកំណត់ពន្យល់ដូចមានចែងក្នុងឧបសម្ព័ន្ធ ក នៃប្រកាសនេះ និងបណ្ដាសេចក្ដីណែនាំដែលចេញដោយនាយកទីចាត់ការគយ និងរដ្ឋាករ ។

ឯកសារភ្ជាប់ជាមួយប្រតិវេទន៍គយ រួមមាន ៖ វិក្កយប័ត្រទំនិញ បញ្ជីវេចខ្ចប់ និងឯកសារដឹកជញ្ជូន ។ ក្នុងករណីចាំបាច់ និវេទន៍ប័ណ្ណ អាជ្ញាប័ណ្ណ លិខិតអនុញ្ញាត វិញ្ញាបនប័ត្រដើមកំណើត វិញ្ញាបនប័ត្រធានារ៉ាប់រង និងឯកសារពាក់ព័ន្ធផ្សេងទៀត ត្រូវភ្ជាប់ជាមួយប្រតិវេទន៍គយ ។

ក្នុងករណីខ្លះ នាយកទីចាត់ការគយ និងរដ្ឋាករ អាចសម្រេចអនុញ្ញាតឲ្យប្រកាសដោយផ្ទាល់មាត់ជំនួសការប្រកាសជាលាយល័ក្ខអក្សរ ។

ប្រតិវេទន៍គយត្រូវតែមានចុះហត្ថលេខាដោយប្រតិវេទករ ។

**ប្រការ ៥.-**

កាលបើទំនិញច្រើនមុខ ត្រូវបានបំពេញក្នុងប្រតិវេទន៍គយតែមួយមុខទំនិញនីមួយៗ ត្រូវបានចាត់ទុកជាកម្មវត្ថុនៃការប្រកាសដោយឡែក ។ មុខទំនិញ នីមួយៗ ត្រូវតែចុះដោយឡែកពីគ្នា និងត្រូវចុះលេខសំគាល់ចំណាត់ថ្នាក់ទំនិញឲ្យបានត្រឹមត្រូវតាមតារាងពន្ធគយជាធរមាន ។

**ប្រការ ៦.-**

កាលបើបុគ្គលមាននីតិសម្បទាធ្វើប្រតិវេទន៍គយ មិនមានព័ត៌មានគ្រប់គ្រាន់សម្រាប់បំពេញប្រតិវេទន៍គយ បុគ្គលនោះអាចត្រូវបានអនុញ្ញាតឲ្យពិនិត្យទំនិញ និងដកទំនិញគំរូមុនពេលបំពេញប្រតិវេទន៍គយ ។ បុគ្គលនោះត្រូវដាក់ប្រតិវេទន៍បណ្តោះអាសន្នជូនគយ ដែលទោះជាក្នុងករណីណាក៏ដោយបុគ្គលនោះមិនអាចរួចផុតពីកាតព្វកិច្ចបំពេញប្រតិវេទន៍គយដែរ ។

ត្រូវហាមឃាត់ដល់រាល់សហត្ថកម្ម ដែលអាចបណ្តាលឲ្យប្រែប្រួលសភាពដើម ឬលក្ខណៈនៃទំនិញដែលជាកម្មវត្ថុនៃការបំពេញប្រតិវេទន៍បណ្តោះអាសន្ន ។

ទម្រង់ប្រតិវេទន៍បណ្តោះអាសន្ន និងលក្ខខណ្ឌនៃការត្រួតពិនិត្យទំនិញមុនពេលបំពេញប្រតិវេទន៍គយត្រូវកំណត់ដោយសេចក្តីសម្រេចរបស់នាយកទីចាត់ការគយ និងរដ្ឋាករ ។

**ប្រការ ៧.-**

ប្រតិវេទន៍គយដែលបានបំពេញត្រឹមត្រូវ និងគ្រប់គ្រាន់ ព្រមទាំងមានភ្ជាប់ជាមួយនូវឯកសារចាំបាច់នានានឹងត្រូវទទួលយកបាន និង ចុះបញ្ជិកាភ្លាមដោយគយ ។

ត្រូវចាត់ទុកថា ជាប្រតិវេទន៍គយដែលមិនអាចទទួលយកបាន និងមិនត្រូវ

បានចុះបញ្ជិកាដោយគយ បណ្តាប្រតិវេទន៍ដែលខុសទម្រង់ ដែលបំពេញមិនបានត្រឹមត្រូវ និងគ្រប់គ្រាន់ ឬមិនបានភ្ជាប់ជាមួយនូវឯកសារចាំបាច់នានា ។ នាយកទីចាត់ការគយ និងរដ្ឋាករ ត្រូវកំណត់នូវលក្ខខណ្ឌនៃការទទួលយកបាននៃប្រតិវេទន៍គយ ។

**ប្រការ ៨.-**

ក្រោយពេលចុះបញ្ជិកាប្រតិវេទន៍គយ ប្រតិវេទករ អាចធ្វើការកែតម្រូវប្រតិវេទន៍គយ តែនៅថ្ងៃចុះបញ្ជិកាប្រតិវេទន៍ និងមុនពេលចាប់ផ្តើមត្រួតពិនិត្យទំនិញជារូបវន្តប៉ុណ្ណោះ ។ ការកែតម្រូវព័ត៌មានអំពី បរិមាណ និងតម្លៃ និងការតម្រូវដែលធ្វើឡើងក្រោយថ្ងៃចុះបញ្ជិកាប្រតិវេទន៍ តម្រូវឲ្យមានការអនុញ្ញាតជាមុនពីទីចាត់ការគយ និងរដ្ឋាករ ។

**ប្រការ ៩.-**

ក្រោយពេលចុះបញ្ជិកាប្រតិវេទន៍គយ និងមុនពេលត្រួតពិនិត្យទំនិញជារូបវន្ត មន្ត្រីគយត្រូវត្រួតពិនិត្យប្រតិវេទន៍គយដើម្បីផ្ទៀងផ្ទាត់ពីភាពគ្រប់គ្រាន់ និងភាពត្រឹមត្រូវនៃព័ត៌មានដែលបានប្រកាសលើប្រតិវេទន៍គយ រួមមាន ដើមកំណើត ចំណាត់ថ្នាក់ទំនិញ តម្លៃគិតពន្ធគយ របបគយ និងចំនួនប្រាក់ពន្ធ និងអាករដែលត្រូវបង់ ។ មន្ត្រីគយត្រូវកែតពិនិត្យផងដែរនូវតម្រូវការចាំបាច់នានា ប្រសិនបើទំនិញនោះជាប្រភេទត្រូវបានហាមឃាត់ ឬជាប់កម្រិតកំណត់ ។

**ប្រការ ១០.-**

ការកែតម្រូវ ការបន្ថែម ការលុប ការបែងចែក និងការគ្រប់គ្រង សុពលភាព និងបណ្តាតម្រូវការផ្សេងទៀតនៃប្រតិវេទន៍ និងបណ្តាឯកសារគយត្រូវធ្វើឡើងតាមទម្រង់ និងរបៀបដែលកំណត់ដោយនាយកទីចាត់ការគយ និងរដ្ឋាករ ។

**ប្រការ ១១.-**

បន្ទាប់ពីបានត្រួតពិនិត្យឯកសារប្រតិវេទន៍គយ មន្ត្រីគយអាចជ្រើសរើសត្រួត

# ឧបសម្ព័ន្ធ «ក»

## I. កំណត់ពន្យល់ប្រភេទប្រតិវេទន៍គយនាំចូល (ឯកសាររដ្ឋបាលតែមួយ)

ឯកសាររដ្ឋបាលតែមួយ (SAD) គឺជាឯកសារតែមួយប្រើសម្រាប់គ្រប់របបបញ្ចេញទំនិញពីគយ ការនាំចូល ការនាំចេញ កណ្តាគារគយ ។ល។ ផ្នែកនេះបង្ហាញលំអិតអំពីរបៀបបំពេញ SAD សំរាប់ប្រតិវេទន៍គយនាំចូល ។ ប្រតិវេទន៍គយនាំចូលរួមមាន:

- ការនាំចូលស្ថាពរ (ដោយផ្ទាល់) / ការនាំចូលដើម្បីប្រើប្រាស់ក្នុងស្រុក - IM4
- ការនាំចូលបណ្តោះអាសន្ន - IM5
- ការនាំចូលមកវិញ - IM6
- ការនាំចូលក្នុងកណ្តាគារគយ - IM7
- ឆ្លងកាត់ - IM8
- តំបន់រួចពន្ធ / តំបន់សេដ្ឋកិច្ចពិសេស - IM9

ប្រអប់និមួយៗនៃ SAD ត្រូវបានរៀបចំឡើង ដែលជាការបញ្ចូលចាំបាច់ (វាត្រូវតែបំពេញ) បញ្ចូលដោយជ្រើសរើស(បំពេញប្រសិនបើមានពាក់ព័ន្ធ) ឬក្នុងករណីខ្លះប្រអប់អាចមិនចាំបាច់បំពេញ(មិនត្រូវការប្រើប្រាស់)។

ផ្នែកខាងក្រោមនេះ រៀបរាប់លំអិតពីគោលបំណងនៃប្រអប់និមួយៗនៃ SAD នៅពេលអនុវត្តប្រតិវេទន៍គយនាំចូល។ ប្រអប់និមួយៗត្រូវបានបរិយាយពីលំដាប់នៃការបញ្ចូលព័ត៌មាន ថាតើវាជាប្រអប់ចាំបាច់ ឬជាប្រអប់ជម្រើស។ ប្រអប់ខ្លះ តម្រូវឱ្យបញ្ចូលលេខកូដយោង ឬឈ្មោះតំណាងអោយព័ត៌មានយោងតាមស្តង់ដារ។ កូដយោងប្រើក្នុងកំណត់ពន្យល់នេះនឹងចេញដោយទីចាត់ការគយ និងរដ្ឋាករ។

**ការពន្យល់នៃប្រអប់ SAD សំរាប់ប្រភេទប្រតិវេទន៍នាំចូល**

| លេខប្រអប់ | ស្លាកសញ្ញាប្រអប់ | សកម្មភាព | បរិយាយ និង / ឬ ការប្រើប្រាស់ |
|---|---|---|---|
| 1 | ប្រភេទប្រតិវេទន៍ | ចាំបាច់ | ដើម្បីកំណត់ថាតើប្រតិវេទន៍ទំនិញត្រូវបានដាក់សំរាប់ការនាំចូល ការនាំចេញ ឬ ក៏ជាការឆ្លងកាត់គយ។<br>លេខគំរូប្រតិវេទន៍ត្រូវបានដាក់បញ្ចូលលើទម្រង់ SAD ក្នុងប្រអប់នេះ។<br>សំរាប់ប្រតិវេទន៍នាំចូលទាំងអស់ គំរូនេះគឺ "IM" ជាមួយនឹងលេខ ដើម្បីកំណត់ថាតើរបបមួយណាជាការនាំចូល ឧទាហរណ៍លេខ ៤ សំរាប់ (នាំចូលប្រើប្រាស់ក្នុងស្រុក)លេខ ៧ សំរាប់ (ស្តុកក្នុងឃ្លាំង)។ល។ |
| A: | ការិយាល័យដាក់ប្រតិវេទន៍: ការិយាល័យគយដែលប្រតិវេទន៍ត្រូវបានដាក់ជូនមន្ត្រីគយពិនិត្យ | | |
| | កូដការិយាល័យ | ចាំបាច់ | កូដនិងឈ្មោះការិយាល័យគយដែលប្រតិវេទន៍ (SAD) ត្រូវបានដាក់និងដំណើរការ។<br>ការិយាល័យគយដែល SAD ត្រូវបានដាក់អាចផ្សេងពីការិយាល័យគយដែលទំនិញត្រូវបាននាំចូល/នាំចេញពីប្រទេស (ប្រអប់លេខ២៩)។<br>នៅពេលប្រើប្រព័ន្ធអាស៊ីគូដា នឹងបង្ហាញដោយស្វ័យប្រវត្តិនូវឈ្មោះ |

| | | | |
|---|---|---|---|
| | | ចាំបាច់ | ផ្នែកទី២ គឺជាកូដរបបបន្ថែម បានប្រើប្រាស់ដើម្បីកំណត់របបរួមឬការលើកលែងពន្ធណាមួយ។<br>នីតិវិធីទាំងពីរខាងលើត្រូវតែឯកភាពគ្នា |
| 38 | ទម្ងន់សុទ្ធ | ចាំបាច់ | ប្រអប់នេះត្រូវបំពេញនូវទម្ងន់សុទ្ធគិតជាគ.ក្រ. នៃទំនិញដែលបានប្រកាស។ ប្រព័ន្ធនឹងបង្ហាញដោយស្វ័យប្រវត្តនូវតួលេខទម្ងន់សរុបដូចទម្ងន់សុទ្ធ។ ប៉ុន្តែអ្នកអាចសរសេរត្រួតគ្នា នៅក្នុងប្រអប់នេះជាមួយនឹងទម្ងន់សុទ្ធ។ |
| 39 | | មិនតម្រូវ | ប្រអប់នេះសំរាប់ការយោងចំពោះទំនិញដែលអនុវត្តកូតាណាមួយ ប្រអប់នេះមិនតម្រូវសំរាប់ពេលប្ចុប្បន្ននេះទេ។ |
| 40 | ឯកសារដឹកជញ្ជូនឬប្រតិវេទន៍យោងពីមុន | ជម្រើស | ប្រអប់នេះសំរាប់បំពេញដូចខាងក្រោម៖<br>លេខអញ្ញាត្តប័ណ្ណ លេខអញ្ញាត្តប័ណ្ណតាមផ្លូវអាកាស ឬ Parcels Notification Duty Entry សំរាប់កិច្ចប្រតិបត្តិការគយដោយផ្ទាល់ ឬ ការយោងប្រតិវេទន៍ពីមុនសំរាប់កិច្ចប្រតិបត្តិការគយប្រយោល ។<br>ឧទាហរណ៍<br>ទំនិញត្រូវបាននាំចូលតាមផ្លូវអាកាស ហើយដាក់ចូលដោយផ្ទាល់ទៅក្នុងឃ្លាំង។ កិច្ចប្រតិបត្តិការនេះ ត្រូវបានចាត់ទុកថាជាកិច្ចប្រត្តិបត្តិការនាំចូលដោយផ្ទាល់ និងកូដរបបគយគឺ ៧១០០។ លេខអញ្ញាត្តប័ណ្ណតាមផ្លូវអាកាសនឹងត្រូវបានបញ្ចូលទៅក្នុងប្រអប់ ៤០ ដើម្បីកាត់ចេញ។<br>បន្ទាប់មក ទំនិញដដែលនេះត្រូវបានយកចេញពីឃ្លាំង និងដាក់លក់ក្នុងទីផ្សារ។ ប្រតិបត្តិការនេះមិនមែនជាប្រត្តិបត្តិការនាំចូលដោយផ្ទាល់នោះទេ ប៉ុន្តែជាការនាំចូលប្រើប្រាស់ក្នុងស្រុកបន្ទាប់ពីបានដាក់ចូលក្នុងឃ្លាំង ដូចនេះរបបគយគឺ ៤០៧១ ។ ការយោងប្រតិវេទន៍ដើម ៧១០០ នឹងត្រូវបានដាក់បញ្ចូលក្នុងប្រអប់ ៤០ សំរាប់តែជាព័ត៌មានតែប៉ុណ្ណោះ។ |
| 41 | ឯកតារង | ចាំបាច់ | ប្រអប់នេះត្រូវបានបំពេញនៅពេលចំណាត់ថ្នាក់តារាងពន្ធគយតាមមុខទំនិញដែលកំពុងប្រើប្រាស់តម្រូវអោយមានឯកតារងក្រៅពីទម្ងន់សុទ្ធដូចជា លីត្រ ចំនួន ឡ ។ល។ មានតែបរិមាណមួយគត់ត្រូវបានបំពេញក្នុងប្រអប់នេះ ឯកតាមិនត្រូវបានដាក់បញ្ចូលទេ។<br>ឧទាហរណ៍<br>i) លេខកូដ 87120010 (កង់ប្រណាំង) ឯកតារង = Unit ដូចនេះប្រអប់ នេះត្រូវបំពេញចំនួនកង់ដែលនាំចូល (ឧ. ៨៣ Unit)។ |
| 42 | តម្លៃឯកតា(តាមមុខទំនិញ) | ចាំបាច់ | ប្រអប់នេះត្រូវបានបំពេញជាមួយតម្លៃតាមមុខទំនិញគិតជារូបិយប័ណ្ណ។<br>វាត្រូវបានបង្ហាញដោយស្វ័យប្រវត្តិ នៅពេលអនុវត្តប្រព័ន្ធអាស៊ីគូដានិងកំណត់សំគាល់តម្លៃត្រូវបានប្រើប្រាស់។ មិនដូច្នេះទេ តម្លៃតាមមុខទំនិញត្រូវបានបញ្ចូលដោយដៃ។ |
| 43 | វិធីកំណត់តម្លៃ | ជម្រើស | ប្រអប់នេះត្រូវបំពេញកូដនៃវិធីកំណត់តម្លៃ (១ដល់៦ និង៩) ត្រូវបានប្រើ |

# ព្រះរាជាណាចក្រកម្ពុជា
## ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

លេខ..៧៥២..សហវ.....ប្រក

# ប្រកាស
## ស្តីពី
## ការដាក់ឱ្យប្រើប្រាស់តារាងពន្ធគយកម្ពុជាឆ្នាំ ២០២២

## ឧបនាយករដ្ឋមន្ត្រី
## រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញ ព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី០៦ ខែកញ្ញា ឆ្នាំ២០១៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញ ព្រះរាជក្រឹត្យលេខ នស/រកត/០៣២០/៤២១ ចុះថ្ងៃទី៣០ ខែមីនា ឆ្នាំ២០២០ ស្តីពីការតែងតាំង និងកែសម្រួលសមាសភាពរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញ ព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញ ព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានឃើញ ព្រះរាជក្រមលេខ នស/រកម/០២៩៧/០៣ ចុះថ្ងៃទី២៤ ខែកុម្ភៈ ឆ្នាំ១៩៩៧ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីសារពើពន្ធ
- បានឃើញ ព្រះរាជក្រមលេខ នស/រកម/០១០៣/០០១ ចុះថ្ងៃទី២០ ខែមករា ឆ្នាំ២០០៣ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការអនុម័តយល់ព្រមឱ្យព្រះរាជាណាចក្រកម្ពុជាចូលរួមក្នុងអនុសញ្ញាអន្តរជាតិស្តីពីការធ្វើឱ្យស៊ីចង្វាក់គ្នានៃការកំណត់មុខទំនិញនិងប្រព័ន្ធលេខកូដ
- បានឃើញ ព្រះរាជក្រមលេខ នស/រកម/០៧០៧/០១៧ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ២០០៧ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីគយ
- បានឃើញ អនុក្រឹត្យលេខ ៧៥ អនក្រ.បក ចុះថ្ងៃទី២៥ ខែឧសភា ឆ្នាំ២០១៧ ស្តីពីការកែសម្រួលអនុក្រឹត្យលេខ ៤៨៨ ចុះថ្ងៃទី១៦ ខែតុលា ឆ្នាំ២០១៣ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ ១៣៤ អនក្រ.បក ចុះថ្ងៃទី១៥ ខែកញ្ញា ឆ្នាំ២០០៨ ស្តីពីការតម្លើងទីចាត់ការគយនិងរដ្ឋាករ នាយកដ្ឋានពន្ធដារ និងរតនាគារជាតិនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ឱ្យទៅជាអគ្គនាយកដ្ឋានគយនិងរដ្ឋាករកម្ពុជា អគ្គនាយកដ្ឋានពន្ធដារ និងអគ្គនាយកដ្ឋានរតនាគារជាតិ ស្ថិតក្រោមការគ្រប់គ្រងរបស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានឃើញ អនុក្រឹត្យលេខ ១៧៧ អនក្រ.បក ចុះថ្ងៃទី ២០ ខែតុលា ឆ្នាំ២០២០ ស្តីពីការកែសម្រួលអត្រាអាករពិសេសលើផលិតផលតេលសិលាមួយចំនួន

- បានឃើញ អនុក្រឹត្យលេខ ២០៨ អនក្រ.បក ចុះថ្ងៃទី១៦ ខែធ្នូ ឆ្នាំ២០២០ ស្តីពីការកែសម្រួលអត្រាពន្ធគយ និងអត្រាអាករពិសេស លើមុខទំនិញមួយចំនួន
- បានឃើញ អនុក្រឹត្យលេខ ១៨ អនក្រ.បក ចុះថ្ងៃទី០៩ ខែកុម្ភៈ ឆ្នាំ២០២១ ស្តីពីការកែសម្រួលអត្រាអាករពិសេស លើមុខទំនិញរថយន្តមួយចំនួន
- បានឃើញ អនុក្រឹត្យលេខ ២២៩ អនក្រ.បក ចុះថ្ងៃទី១៧ ខែវិច្ឆិកា ឆ្នាំ២០២១ ស្តីពីការកំណត់ និងកែសម្រួលអត្រាពន្ធគយ អត្រាអាករពិសេស និងអត្រាអាករនាំចេញ
- បានឃើញ ពិធីសារទី២ ស្តីពីការកែសម្រួលពិធីសារអនុវត្តនាមវលីនៃតារាងពន្ធគយស៊ីចង្វាក់របស់អាស៊ាន (AHTN) ចុះថ្ងៃទី០៨ ខែមេសា ឆ្នាំ២០១០ នៅទីក្រុងញ៉ាត្រាង ប្រទេសវៀតណាម
- បានឃើញ ប្រកាសលេខ ១១១៩ សហវ.ប្រក ចុះថ្ងៃទី០៦ ខែតុលា ឆ្នាំ២០១៦ ស្តីពីការដាក់ឱ្យប្រើប្រាស់តារាងពន្ធគយកម្ពុជាឆ្នាំ ២០១៧
- យោងតាមតម្រូវការចាំបាច់របស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។

**សម្រេច**

**ប្រការ ១**.- ដាក់ឱ្យប្រើប្រាស់តារាងពន្ធគយកម្ពុជាឆ្នាំ ២០២២ ដូចមានភ្ជាប់ជាមួយនេះ ស្របតាមនាមវលីនៃតារាងពន្ធគយស៊ីចង្វាក់អាស៊ានឆ្នាំ ២០២២ (AHTN 2022) ចាប់ពីថ្ងៃទី០១ ខែមករា ឆ្នាំ២០២២ នេះតទៅ។

**ប្រការ ២**.- រាល់មុខទំនិញនាំចេញនាំចូល ត្រូវជាប់ពន្ធគយ អាករពិសេស អាករលើតម្លៃបន្ថែម និងអាករនាំចេញ តាមអត្រាដូចមានចែងលម្អិតក្នុងតារាងពន្ធគយនេះ។

**ប្រការ ៣**.- បទប្បញ្ញត្តិទាំងឡាយណាដែលមានខ្លឹមសារផ្ទុយពីប្រកាសនេះ ត្រូវទុកជានិរាករណ៍។

**ប្រការ ៤**.- រដ្ឋមន្ត្រីប្រតិភូអមនាយករដ្ឋមន្ត្រី នាយកខុទ្ទកាល័យ អគ្គលេខាធិការ ប្រតិភូរាជរដ្ឋាភិបាលទទួលបន្ទុកជាអគ្គនាយកនៃអគ្គនាយកដ្ឋាន អគ្គនាយកនៃអគ្គនាយកដ្ឋាន អគ្គាធិការនៃអគ្គាធិការដ្ឋាន នាយកនៃវិទ្យាស្ថានសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងគ្រប់ប្រធានអង្គភាពនានាក្រោមឱវាទក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ត្រូវទទួលបន្ទុកអនុវត្តប្រកាសនេះ តាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ។

ថ្ងៃអាទិត្យ ១០កើត ខែ កត្តិក ឆ្នាំឆ្លូវ ត្រីស័ក ព.ស. ២៥៦៥
ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ១៤ ខែ វិច្ឆិកា ឆ្នាំ២០២១

ឧបនាយករដ្ឋមន្ត្រី
រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

អគ្គបណ្ឌិតសភាចារ្យ អូន ព័ន្ធមុនីរ័ត្ន

**កន្លែងទទួល៖**

- ទីស្តីការគណៈរដ្ឋមន្ត្រី
- ខុទ្ទកាល័យ**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា**
- ខុទ្ទកាល័យសម្តេច ឯកឧត្តម លោកជំទាវ ឧបនាយករដ្ឋមន្ត្រី
- ដូចប្រការ ៤
- សភាពាណិជ្ជកម្មកម្ពុជា
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ